**កិច្ចប្រជុំលើកទី ១៧**

**គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍**

**ភ្នំពេញ ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០**

៚៚៚•៙៙៙

# សុន្ទរកថាស្វាគមន៍

## របស់ឧបនាយករដ្ឋមន្ត្រី គាត ឈន់

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធានទី១នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## ប្រធានគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍

- *លោកជំទាវ ឯកឧត្តម សហសេវិកក្នុងរាជរដ្ឋាភិបាល*
- *លោកជំទាវ ឯកឧត្តម ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត និងតំណាងដៃគូអភិវឌ្ឍន៍*
- *លោកជំទាវ ឯកឧត្តម លោកស្រី អស់លោក*

១- ខ្ញុំសូមសំដែងការស្វាគមន៍យ៉ាងកក់ក្តៅចំពោះការអញ្ជើញចូលរួមរបស់លោកជំទាវ ឯកឧត្តម លោកស្រី អស់លោកនៃស្ថាប័នរបស់រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍និងសង្គមស៊ីវិល ក្នុងកិច្ចប្រជុំលើកទី១៧នៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ (GDCC) នៅវិមានរដ្ឋាភិបាលនាពេលព្រឹកនេះ ។

២- បន្ទាប់ពីវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣ប្រកបដោយជោគជ័យ នាថ្ងៃទី២- ៣ខែមិថុនា ឆ្នាំ២០១០មក ខ្ញុំមានក្តីសោមនស្សរីករាយ ដោយបានកត់សំគាល់នូវវឌ្ឍនភាពលេចធ្លោជាច្រើនក្នុងវិស័យសង្គម និងសេដ្ឋកិច្ច ព្រមទាំងក្នុងកំណែទម្រង់ស្ទូលរបស់រាជរដ្ឋាភិបាល ។ កម្មវិធីជាតិស្តីពីការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិត្រូវបានប្រកាសឱ្យអនុវត្តនាថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១០ ។រីឯកំណែទម្រង់ដទៃក៏កំពុងមានវឌ្ឍនភាព ហើយក្នុងអង្គប្រជុំព្រឹកនេះ យើងទាំងអស់គ្នានឹងទទួលព័ត៌មានបច្ចុប្បន្នភាពស្តីពីវឌ្ឍនភាពក្នុងកំណែទម្រង់រដ្ឋបាល ដែលនេះជារបៀបវារៈមួយនៃកិច្ចប្រជុំរបស់យើង ។ លើសពីនេះ ក៏មានការវិវត្តន៍ជាវិជ្ជមានផងដែរនៅក្នុងវិស័យសេដ្ឋកិច្ច ដោយវិស័យធនាគារបានរាយការណ៍អំពីកំណើនក្នុងការផ្តល់ឥណទាន ។ រីឯកំណើនសេដ្ឋកិច្ចវិញក៏កំពុងត្រូវបានពិនិត្យឡើងវិញ ដោយសង្ឃឹមថាអាចសម្រេចបានក្នុងកម្រិតខ្ពស់ជាងការប៉ាន់ស្មានពីដើមឆ្នាំ ។

៣- យើងមានមោទនភាពលើសមិទ្ធផលទាំងឡាយដែលសម្រេចបានក្នុងការអនុវត្តន៍«យុទ្ធសាស្រ្តចតុកោណ-ដំណាក់កាលទី២»កន្លងមក ហើយយើងមានសុទិដ្ឋិនិយមថា ស្ថានភាពសេដ្ឋកិច្ចកម្ពុជានឹងត្រឡប់មកភាពល្អប្រសើរវិញ ដោយសង្ឃឹមថាកំណើនសេដ្ឋកិច្ចនឹងមានកម្រិតខ្ពស់ដូចរយៈពេលប៉ុន្មានឆ្នាំកន្លងមក ទន្ទឹមនឹងពេលដែលរាជរដ្ឋាភិបាលកំពុងបន្តពង្រឹងខឿនសេដ្ឋកិច្ចកម្ពុជា សម្រាប់ឆ្លើយតបទៅនឹងវិបត្តិសេដ្ឋកិច្ចសកលជាយថាហេតុនាពេលអនាគត ។ វិធានការដ៏សំខាន់មួយដែលបានគូសបញ្ជាក់ដោយ **សម្តេច អគ្គមហាសេនាបតីតេជោ**

**ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា គឺពិពិធភាវូបនីយកម្មសេដ្ឋកិច្ច ការស្វែងរកទីផ្សារថ្មី និងការបង្កើនតំលៃបន្ថែមសម្រាប់ផលិតផលនាំចេញរបស់កម្ពុជា ។ ក្នុងស្មារតីនេះ **សម្តេច នាយករដ្ឋមន្ត្រី** បានផ្តួចផ្តើម និងដឹកនាំដំណើរការរៀបចំ «ឯកសារគោលនយោបាយស្តីពីការជម្រុញផលិតកម្មស្រូវនិងការនាំចេញអង្ករ» ។ ខ្ញុំក៏បានដឹងដែរថា លោកជំទាវ ឯកឧត្តម លោកស្រី អស់លោកមួយចំនួនក្នុងរាជរដ្ឋាភិបាល បានចូលរួមតាក់តែង ពិភាក្សា និងអនុមតិឯកសារគោលនយោបាយនេះ ហើយខ្ញុំសូមវាយតំលៃខ្ពស់និងសូមកោតសរសើរចំពោះកិច្ចសហការក្នុងកិច្ចការនេះ ។ ទន្ទឹមនឹងនេះ ខ្ញុំក៏បានដឹងដែរថា ដៃគូអភិវឌ្ឍន៍របស់យើងបាននិងកំពុងតាមដានដោយយកចិត្តទុកដាក់ខ្ពស់ ហើយមានឆន្ទៈផ្តល់ការគាំទ្រសម្រាប់អនុវត្តគោលនយោបាយដ៏សំខាន់នេះ ។ ឆ្លៀតឱកាសដ៏ប្រពៃនេះ ខ្ញុំសូមវាយតំលៃចំពោះការគាំទ្រនិងកិច្ចសហប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍន៍ទាំងអស់ ហើយខ្ញុំសូមអនុញ្ញាតរៀបរាប់ដោយសង្ខេបអំពីចំណុចគន្លឹះសំខាន់ៗនៃឯកសារគោលយោបាយនេះ ។

- *លោកជំទាវ ឯកឧត្តម លោកស្រី អស់លោក*

៤- ក្រោមចក្ខុវិស័យនិងកិច្ចដឹកនាំផ្ទាល់ប្រកបដោយគតិបណ្ឌិតរបស់ **សម្តេច នាយករដ្ឋមន្ត្រី** «ឯកសារគោលនយោបាយស្តីពីការជម្រុញផលិតកម្មស្រូវនិងការនាំចេញអង្ករ» បានបញ្ជាក់យ៉ាងច្បាស់អំពីកាលានុវត្តភាពដ៏ធំធេងសម្រាប់កម្ពុជា និងបញ្ហាប្រឈមដែលត្រូវដោះស្រាយក្នុងពិពិធភាវូបនីយកម្មសេដ្ឋកិច្ច និងការលើកកំពស់ជីវភាពរស់នៅរបស់ប្រជាជននៅជនបទ ។ ទោះបីជាគោលដៅចម្បងនៃឯកសារគោលនយោបាយនេះបានផ្តោតលើ«ការនាំចេញអង្ករ»ក៏ដោយ ក៏ការវិនិយោគក្នុងវិស័យផលិតកម្ម ការកែច្នៃ ការពង្រីកទីផ្សា និងការកសាងហេដ្ឋារចនាសម្ព័ន្ធក៏មានឥទ្ធពលជាវិជ្ជមានជាច្រើនដល់វិស័យដទៃទៀតនៃខឿនសេដ្ឋកិច្ចកម្ពុជាផងដែរ ។ ឯកសារគោលនយោបាយនេះបានប្រមូលផ្តុំការយកចិត្តទុកដាក់លើសរសរគ្រឹះពាសំខាន់ គឺ ÷

ក- ការបង្កើនផលិតភាព

ខ- ពិពិធភាវូបនីយកម្មផលិតកម្ម និងទីផ្សា និង

គ- ពាណិជ្ជូបនីយកម្មផលិតផលកសិកម្ម ។

៥- ចំពោះបញ្ហាប្រឈមវិញ រាជរដ្ឋាភិបាលនឹងរកដំណោះស្រាយពេញលេញសម្រាប់ឆ្លើយតបទៅនឹងបញ្ហាប្រឈមនិមួយៗ ហើយដៃគូអភិវឌ្ឍន៍អាចផ្តល់ការគាំទ្ររបស់ខ្លួនសម្រាប់អនុវត្តសកម្មភាពអាទិភាពដែលបានកំណត់ក្នុងឯកសារគោលនយោបាយរបស់រាជរដ្ឋាភិបាល ដូចខាងក្រោម ÷

ក- <u>ក្នុងវិស័យកសិកម្ម</u> : គាំទ្រដល់ការអនុវត្តន៍«យុទ្ធសាស្ត្រជាតិស្តីពីកសិកម្មនិងទឹក» ពិសេសក្នុងវិស័យធារាសាស្ត្រ ការប្រើប្រាស់បច្ចេកវិជ្ជា និងការគ្រប់គ្រងនិងការប្រើប្រាស់ជីធ្លី ធនធានទឹក គ្រាប់ពូជ និងធាតុចូលដទៃទៀត ។

ខ- <u>ក្នុងពាណិជ្ជកម្ម</u> : ជម្រុញការចូលរួមរបស់វិស័យឯកជននៅក្នុងគ្រប់ដំណាក់កាលនៃ «ខ្សែសង្វាក់តំលៃ-Value Chain» រួមទាំងសកម្មភាពក្រោយពេលប្រមូលផល ការចូលរួមលើកកំពស់ស្តង់ដារសម្រាប់ការនាំចេញ និងដោះស្រាយបញ្ហារាំងស្ទះនានា ព្រមទាំងសកម្មភាពផ្សព្វផ្សាយ និងជម្រុញអង្ករកម្ពុជានៅលើទីផ្សាអន្តរជាតិ ។

គ- <u>ក្នុងវិស័យហិរញ្ញវត្ថុ</u> : ពិនិត្យឡើងវិញប្រព័ន្ធលើកទឹកចិត្តខាងផ្នែកពន្ធដារ កិច្ចដំណើរការរបស់ទីផ្សាឥណទាន ប្រព័ន្ធមីក្រូហិរញ្ញវត្ថុ និងកិច្ចប្រឹងប្រែងសម្រាប់ជម្រុញការនាំចេញអង្ករផ្លូវការ ។

ឃ- ក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ : ពិនិត្យបញ្ហាដែលពាក់ព័ន្ធនឹងវិស័យថាមពល ប្រព័ន្ធដឹកជញ្ជូន ដើម្បីធានាថាការកែច្នៃ និងការរក្សាទុកដាក់ ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន អាចជួយបង្កើនការនាំចេញអង្ករ ទាំងខាងគុណភាព និងទាំងខាងបរិមាណ ។

ង- ចំពោះការអភិវឌ្ឍន៍នៅថ្នាក់ក្រោមជាតិ : សំណើនិងការខ្វាយខ្វល់របស់ប្រជាកសិករនឹងត្រូវបានរំលេចនៅក្នុងផែនការអភិវឌ្ឍន៍នៅថ្នាក់ក្រោមជាតិ ។

ច- ក្នុងវិស័យសង្គមកិច្ច : បញ្ហានានាដែលពាក់ព័ន្ធនឹងសន្តិសុខស្បៀងនិងការគាំពារសង្គមនឹងត្រូវដោះស្រាយតាមអភិក្រមគ្រប់ជ្រុងជ្រោយនៃកិច្ចអភិវឌ្ឍន៍កសិកម្ម និងជនបទ ។

- *លោកជំទាវ ឯកឧត្តម លោកស្រី អស់លោក*

៦- ខ្ញុំសង្ឃឹមថា បណ្តាចំណុចគន្លឹះសំខាន់ៗនៃឯកសារគោលនយោបាយដូចបានរៀបរាប់នេះនឹងផ្តល់ជាគុណប្រយោជន៍សម្រាប់លោកជំទាវ ឯកឧត្តម លោកស្រី អស់លោក ហើយយើងអាចពិភាក្សាប្រធានបទនេះក្នុងរបៀបវារៈ«បញ្ហាផ្សេងៗ» ប្រសិនបើយល់ឃើញថាមានការចាំបាច់ ។ ការជម្រុញផលិតកម្មស្រូវនិងការនាំចេញអង្ករ គឺជាគោលនយោបាយស្នូលដែលយើងទាំងអស់គ្នាត្រូវអនុវត្តឱ្យបានសម្រេច ព្រោះគោលនយោបាយនេះអាចគ្របដណ្តប់លើបញ្ហាជាច្រើន ដែលពាក់ព័ន្ធនឹងកំណើនសេដ្ឋកិច្ច ការលើកកំពស់ជីវភាពរស់នៅ សន្តិសុខស្បៀង និងការគាំពារផ្នែកសង្គម ។ យើងបានរៀបចំនិងកំពុងអនុវត្តកម្មវិធីសហប្រតិបត្តិការជាច្រើននៅក្នុងវិស័យជាច្រើនរួចមកហើយ ។ លើសពីនេះ យើងក៏បានឯកភាពលើគោលការណ៍គ្រឹះសម្រាប់កិច្ចសហប្រតិបត្តិការរបស់យើងផងដែរ ។ គោលការណ៍ទាំងនោះគឺ «ភាពជាដៃគូ ការគោរពគ្នាទៅវិញទៅមក ប្រសិទ្ធភាព និងគណនេយ្យភាពទិសដោយផ្តោតលើលទ្ធផល» ហើយគោលការណ៍ទាំងអស់នៅតែជាមូលដ្ឋានគ្រឹះសម្រាប់អនុវត្ត «ឯកសារគោលនយោបាយស្តីពីការជម្រុញផលិតកម្មស្រូវនិងការនាំចេញអង្ករ» របស់រាជរដ្ឋាភិបាល ។ លើសពីនេះ ខ្ញុំជឿជាក់ថា យើងនៅមានសក្តានុពលជាច្រើនសម្រាប់ជម្រុញ «ភាពជាដៃគូត្រីភាគីដែលជួយគាំទ្រគ្នាទៅវិញទៅមក - Tripartite and mutually-supportive partnership» រវាងរាជរដ្ឋាភិបាល ផ្នែកឯកជននិងដៃគូអភិវឌ្ឍន៍ ។ លើសពីនេះ ក្នុងកម្រិតតំបន់ ប្រទេសនាំចេញអង្ករធំជាងគេគឺជាប្រទេសជិតខាងរបស់យើង ។ ដូចនេះ យើងមានលទ្ធភាពជាច្រើនក្នុងការពង្រឹង«កិច្ចសហប្រតិបត្តិការត្បូង- ត្បូង - South-South Cooperation» ។ កិច្ចការនានាដែលពាក់ព័ន្ធនឹងការជម្រុញផលិតកម្មស្រូវនិងការនាំចេញអង្ករ បានផ្តល់នូវកាលានុវត្តភាពដ៏ប្រពៃសម្រាប់ពង្រឹងភាពជាដៃគូជាមួយនឹងផ្នែកឯកជននិងបណ្តាដៃគូទាំងអស់ក្នុងតំបន់ ។

- *លោកជំទាវ ឯកឧត្តម លោកស្រី អស់លោក*

៧- ខ្ញុំសូមអញ្ជើញលោកជំទាវ ឯកឧត្តម លោកស្រី អស់លោក ពិនិត្យមើលរបៀបវារៈនៃអង្គប្រជុំរបស់យើង ។ របៀបវារៈទី១នៃកិច្ចប្រជុំនឹងពិនិត្យវឌ្ឍនភាពលើសូចនាករសំខាន់ៗមួយចំនួន សម្រាប់តាមដានសកម្មភាពដែលបានឯកភាពក្នុងវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣ ។ យើងនឹងផ្តោតការពិភាក្សាទៅលើចំណុចសំខាន់ៗដូចតទៅ ÷

ក- ក្នុងការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ យើងនឹងពិនិត្យ និងអនុមតិលើ«សេចក្តីណែនាំថ្មីស្តីពីតួនាទីនិងការប្រព្រឹត្តទៅរបស់ក្រុមការងារបច្ចេកទេសចម្រុះ» និង«ឯកសារទស្សនទានស្តីពីអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី» ដែលបង្ហាញដោយឯកឧត្តម ឈៀង យ៉ាណារ៉ា ។

ខ- ក្រសួងផែនការនឹងជម្រាបអំពីវឌ្ឍនភាពក្នុងការរៀបចំក្របខ័ណ្ឌត្រួតពិនិត្យនិងតាមដានផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងការធ្វើសមាហរណកម្មរវាងការងារផែនការ ថវិកា និងហិរញ្ញប្បទានអភិវឌ្ឍន៍ផ្លូវការ ។

គ- អង្គភាពប្រឆាំងអំពើពុករលួយនឹងលើកបង្ហាញអំពីការរៀបចំស្ថាប័ន និងតម្រូវការធនធាន សម្រាប់អនុវត្តច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ។

ឃ- ក្រុមប្រឹក្សាស្តារនិងអភិវឌ្ឍន៍កសិកម្មនិងជនបទនឹងជម្រាបជូនអំពីវឌ្ឍនភាពក្នុងការរៀបចំយុទ្ធសាស្ត្រជាតិគាំពារសង្គម ។

ង- ចុងបញ្ចប់ យើងនឹងពិភាក្សាអំពីកិច្ចសហប្រតិបត្តិការក្នុងវិស័យច្បាប់និងតុលាការ ដោយផ្តោតជាពិសេសទៅលើច្បាប់ស្តីការរៀបចំនិងការប្រព្រឹត្តទៅរបស់តុលាការ» និង«ច្បាប់ស្តីពីលក្ខន្តិកៈនៃអង្គចៅក្រមនិងព្រះរាជអាជ្ញា» ដែលជាច្បាប់មូលដ្ឋាន២ ដូចមានចែងក្នុងតារាងសូចនាករដែលបានអនុមតិក្នុងវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣ នាខែមិថុនា ឆ្នាំ២០១០កន្លងមក ។

- *លោកជំទាវ ឯកឧត្តម លោកស្រី អស់លោក*

៨- គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (ក.អ.ក/គ.ជ.នា) ក្នុងឋានៈជាលេខាធិការដ្ឋាននៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ បានរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពក្នុងការអនុវត្តន៍សូចនាករតាមដានរួមគ្នា ដោយផ្អែកលើរបាយការណ៍របស់ក្រុមការងារបច្ចេកទេសចម្រុះនិមួយៗ ។ ខ្ញុំសូមលោកជំទាវ ឯកឧត្តម លោកស្រី អស់លោកមេត្តា អានរបាយការណ៍នេះ ហើយសូមយកចិត្តទុកដាក់ដល់បណ្តាចំណុចដែលបានលើកក្នុងរបាយការណ៍នេះដូចតទៅ ÷

ក- ក្រុមការងារបច្ចេកទេសចម្រុះទាំងអស់បានរាយការណ៍ថា មានវឌ្ឍនភាពក្នុងការអនុវត្តន៍ផែនការសកម្មភាពប្រចាំឆ្នាំរបស់ខ្លួន ទោះបីជាមានក្រុមការងារខ្លះ ដូចជាក្រុមការងារកសិកម្មនិងទឹក និងសន្តិសុខស្បៀងនិងអាហារូបត្ថម្ភបានរាយការណ៍ពីកង្វះធនធានសម្រាប់អនុវត្តសកម្មភាពក៏ដោយ ។ រីឯក្រុមការងារខ្លះទៀតបានរាយការណ៍ថា ភាពស្មុគស្មាញនៃការងារ ឬការងារដែលមានការពាក់ព័ន្ធនឹងក្រសួងឬស្ថាប័នជាច្រើនរបស់រាជរដ្ឋាភិបាល តម្រូវឱ្យមានការចូលរួមឱ្យបានសកម្មថែមទៀតពីមន្ត្រីជាន់ខ្ពស់របស់ស្ថាប័នទាំងនេះ ។

ខ- នៅស្ទើរគ្រប់ក្រុមការងារបច្ចេកទេសចម្រុះទាំងអស់ របាយការណ៍បានបញ្ជាក់ថា មានវឌ្ឍនភាពក្នុងការអនុវត្តន៍សូចនាករតាមដានរួមគ្នា ដែលបានអនុមតិក្នុងវេទិកាសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី៣ ។ នៅក្នុងករណីជាច្រើន វឌ្ឍនភាពនៃការអនុវត្តន៍សូចនាករទាំងនេះត្រូវចំណុះទៅនឹងការកែលំអកិច្ចដំណើរការរៀបចំផែនការ ថវិកា និងយន្តការពិគ្រោះយោបល់ ។ ទោះជាយ៉ាងនេះក្តីក៏បញ្ហាកង្វះធនធានបានក្លាយជាបញ្ហាប្រឈមក្នុងការអនុវត្តន៍សូចនាកររបស់ក្រុមការងារ ដូចដែលក្រុមការងារខ្លះ (កសិកម្មនិងទឹក អប់រំ ព្រៃឈើនិងបរិដ្ឋាន ទេសាទ សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ

ហេដ្ឋារចនាសម្ព័ន្ធនិងសមាហរណកម្មតំបន់ ដីធ្លី កំណែទម្រង់ច្បាប់និងតុលាការ ការដោះមីន ការផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យ) បានលើកឡើង ។ ខ្ញុំសង្ឃឹមថា បញ្ហានេះនឹងអាចដោះស្រាយបាន ក្នុងកម្រិតក្រុមការងារនិមួយៗ ។ បើពុំនោះសោតទេ បញ្ហានេះនឹងត្រូវយកមកដោះស្រាយ នៅក្នុងកិច្ចប្រជុំលើកក្រោយរបស់គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ។

គ- ប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការត្រូវបានបញ្ជ្រាបប្រកបដោយប្រសិទ្ធភាពទៅក្នុងកិច្ចការរបស់ក្រុមការងារ ដែលអាចចូលរួមក្នុងការអនុវត្តន៍ឱ្យសម្រេចចេញជាលទ្ធផល ។ ការកែសម្រួលសេចក្តីណែនាំស្តីពីតួនាទីនិងការប្រព្រឹត្តទៅរបស់ក្រុមការងារបច្ចេកទេសចម្រុះនិងឯកសារទស្សនទានស្តីពីអភិក្រម គ្រប់គ្រងទូទាំងកម្មវិធី ដែលខ្ញុំសង្ឃឹមថាយើងអាចអនុមតិក្នុងកិច្ចប្រជុំនេះ នឹងបង្កើតជាចលនការថ្មីបន្ថែមទៀតសម្រាប់ពង្រឹងប្រសិទ្ធភាពនៃកិច្ចសហការរបស់យើង ។

- *លោកជំទាវ ឯកឧត្តម លោកស្រី អស់លោក*

៩- រីឯរបៀបវារៈទី២របស់កិច្ចប្រជុំ គឺការពិនិត្យវឌ្ឍនភាពក្នុងការអនុវត្តន៍កម្មវិធីជាតិកំណែទម្រង់រដ្ឋបាល ។ ខ្ញុំក៏ដឹងដែរថានៅមានការពិភាក្សាជាបន្តបន្ទាប់លើការងារដែលពាក់ព័ន្ធនឹងការអនុវត្តន៍ «ចំណាយប្រតិបត្តិការអាទិភាព» ដែលយើងអាចលើកយកមកពិភាក្សានាពេលនេះ ។ ក៏ប៉ុន្តែ គោលដៅចម្បងនៃកិច្ចប្រជុំលើកនេះ គឺផ្តោតទៅលើបណ្តាបញ្ហា និងអាទិភាពក្នុងអនុវត្តន៍កម្មវិធីកំណែទម្រង់វិស័យសាធារណៈ ។ សហសេវិករបស់ខ្ញុំ ដែលតំណាងឱ្យក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលនឹងធ្វើបទបង្ហាញលើរបៀបវារៈទី២នេះ ។

- *លោកជំទាវ ឯកឧត្តម លោកស្រី អស់លោក*

១០- ខ្ញុំសូមបញ្ចប់សុន្ទរកថាស្វាគមន៍ត្រឹមនេះ ដោយសង្ឃឹមថាសុន្ទរកថាស្វាគមន៍នេះបានកំណត់ច្បាស់លាស់អំពីរបៀបដំណើរការនៃអង្គប្រជុំរបស់យើង ។ ខ្ញុំសូមស្នើលោកជំទាវ ឯកឧត្តម លោកស្រី អស់លោកមេត្តាផ្តល់វិភាគទាន និងយោបល់ក្នុងន័យស្ថាបនាដល់កិច្ចប្រជុំរបស់យើង និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការយកចិត្តទុកដាក់ស្តាប់របស់លោកជំទាវ ឯកឧត្តម លោកស្រី អស់លោក ។

*សូមអរគុណ*